ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១៤៥/១១-ត្រូពីកាណា (កាស៊ីណូ)
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ សេង រ៉ូចហ៊ុន
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ ទូន ស៊ីផាន់
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ប៉ែន ប៊ុនឈា

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ត្រូពីកាណា (កាស៊ីណូ)**
អាសយដ្ឋាន ៖ ភូមិក្បាលស្ពាន សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
ទូរស័ព្ទ ៖ ០១២ ៩៥៦ ៧៨៩ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖ **អវត្តមាន**

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ . **សហជីពសេរីកម្មករនិយោជិតនៃក្រុមហ៊ុន កាស៊ីណូ ត្រូពីកាណា**
. **សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា**
អាសយដ្ឋាន ៖ ភូមិក្បាលស្ពាន សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
ទូរស័ព្ទ ៖ ០៨៨ ៩៥ ៣៩ ៨០០ ទូរសារ ៖ គ្មាន
តំណាងកម្មករនិយោជិត ៖
- លោក សាត សែប ប្រធានសហជីពសេរីកម្មករនិយោជិតប្រចាំក្រុមហ៊ុន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សុំបិទរូបថតប្រធានសហជីពក្នុងក្រុមហ៊ុន ។

២- សុំរយៈពេល ២ សប្តាហ៍ រៀងរាល់ខែជួបគ្នា ១ ម៉ោង ជួបសហជីពក្រៅម៉ោងការងារ ។

៣- សុំអនុញ្ញាតិប្រើសិទ្ធិ ជំពូកទី១១ នៃច្បាប់ស្តីពីការងារ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជា នឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១៤៧៣ មកប/ខបជ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១១។

## សវនាការ និង សង្ខេបនីតិវិធី

*ទីកន្លែងសវនាការ* ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

*កាលបរិច្ឆេទសវនាការ* ៖ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ (វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក) ។

*បញ្ហានៃនីតិវិធី* ៖

នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបន្ទាយមានជ័យបានទទួលពាក្យបណ្តឹងរបស់សហជីពកម្មករនិយោជិត ស្តីពីការទាមទារចំនួន០៣ចំណុច។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងមកមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបន្ទាយមានជ័យបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់។ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១ អ្នកផ្សះផ្សាបានអញ្ជើញភាគីនៃវិវាទទាំងពីរមកផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការទាមទារតាមនីតិវិធី និងធ្វើការផ្សះផ្សានៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០៣ ចំណុច លើការទាមទារចំនួន ០៣ ចំណុច។ ចំណុចមិនសះជាចំនួន ០៣ ចំណុចនេះត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១១ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ១៤៧៣ មកប/ខបជ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១១។ បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និង

ភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៣ ចំណុចនេះ នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។ ភាគីកម្មករនិយោជិតមានវត្តមាន តាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ប៉ុន្តែភាគីនិយោជកមិនមានវត្តមាននៅក្នុងសវនការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅចំណុចមិនសះជាចំនួន ០៣ ចំណុចនេះបន្ថែមទៀត។ ភាគីកម្មករនិយោជិតយល់ព្រមដកចំណុចវិវាទទី៣ ចេញពីសំណុំរឿងនេះ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖ គ្មាន

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- ចំនួនបុគ្គលិកបំរើការងារនៅក្រុមហ៊ុន ត្រូពីកាណា កាស៊ីណូ ។

២- សេចក្តីជូនដំណឹងរបស់សហជីពសេរីកម្មករនិយោជិតនៃកាស៊ីណូ ត្រូពីកាណា លេខ ០០១ ស.ជ.ក.ត ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១១ ។

៣- ជំពូកទី២២ និងទី១៦ នៃច្បាប់ស្តីពីការងារ ។

៤- អ្នកតំណាងបុគ្គលិកកម្មករនិយោជិត សហជីពសេរីកម្មករនិយោជិត ក្រុមហ៊ុន ត្រូពីកាណា ។

៥- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពសេរីកម្មករនិយោជិតនៃក្រុមហ៊ុន កាស៊ីណូ ត្រូពីកាណា ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១ ។

៦- លិខិតឧទ្ទេសនាមរបស់សមាគមអ្នកនិពន្ធខ្មែរលេខ ០០៧/១១ សអខ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១ ស្តីពីការតែងតាំងលោក សាត សែប មុខងារជាសមាជិកសកម្ម សអខ ។

៧- ពាក្យបណ្តឹងរបស់លោក សាត សែប ប្រធានសហជីពសេរីកម្មករនិយោជិតនៃក្រុមហ៊ុន កាស៊ីណូ ត្រូពីកាណា ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១១ គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបន្ទាយមានជ័យ ស្តីពីបញ្ជិកាអង្គការវិជ្ជាជីវៈសហជីពសេរីកម្មករនិយោជិតនៃក្រុមហ៊ុន កាស៊ីណូ ត្រូពីកាណា ត្រូវបានគណៈគ្រប់គ្រងក្រុមហ៊ុន គឺលោក វិន័យរ៉ូចប ប្រធានការិយាល័យធនធានមនុស្សនៃកាស៊ីណូត្រូពីកាណាច្រានចោលនូវពេលខ្ញុំបាទជាប្រធានសហជីពនេះ បានសុំបង្ហាញរូបថតអ្នកតំណាងកម្មករនិយោជិត ដែលត្រូវបិទតាំងតាមការស្នើសុំពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១១ នោះមកហើយត្រូវបិទនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ ២០១១ នេះ ។

៨- លក្ខន្តិកៈសហជីពសេរីកម្មករនិយោជិតនៃក្រុមហ៊ុន កាស៊ីណូ ត្រូពីកាណា ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ ២០១១ ។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ត្រូពីកាណា (កាស៊ីណូ) លេខ ១៤៧៣ មកប/ខបជ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ត្រូពីកាណា (កាស៊ីណូ) ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ៖

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៨១១ កប/អក/វក/លកអ. ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៨១២ កប/អក/វក/លកអ. ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- តាមរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមហ៊ុន ត្រូពីកាណា (កាស៊ីណូ) មានជួលកម្មករនិយោជិតចំនួន ៦៧២ នាក់ ។ ប៉ុន្តែលោក សាត សែប ប្រធានសហជីពសេរីកម្មករនិយោជិតនៃក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនបានបើកដំណើរការនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០០ ហើយបច្ចុប្បន្នក្រុមហ៊ុនមានជួលកម្មករនិយោជិតសរុបប្រមាណ ១០៨០ នាក់ ក្នុងនោះ ៨០ ភាគរយ ជាកម្មករនិយោជិតផ្នែកកាស៊ីណូ ។
- សហជីពសេរីកម្មករនិយោជិត ជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។ សហជីពនេះទទួលបានបញ្ជិកាសហជីពពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១។ ភាគីសហជីពបញ្ជាក់ថា កម្មករនិយោជិត ដែលជាសមាជិកសហជីព មានចំនួនប្រមាណជាង ១១០ នាក់។ ប៉ុន្តែសហជីពមិនទាន់បានបញ្ជូនឈ្មោះជូនទៅក្រុមហ៊ុននៅឡើយទេ។
- ភាគីសហជីពបានបញ្ជាក់ថា នេះជាលើកដំបូងហើយ ដែលនៅក្នុងក្រុមហ៊ុនមានសហជីព ពីព្រោះកន្លង

មកមិនដែលមានសហជីពនៅក្នុងក្រុមហ៊ុនទេ។ ម្យ៉ាងទៀត ប្រតិភូបុគ្គលិកក៏មិនដែលមានដែរ ព្រោះមិនដែលមានការបោះឆ្នោតជ្រើសរើសតំណាងកម្មករ (ប្រតិភូបុគ្គលិក) ទេ ។

- ភាគីនិយោជកអវត្តមាននៅថ្ងៃសវនាការដោយគ្មានមូលហេតុ។

ចំណុចវិវាទទី១ ៖ កម្មករនិយោជិតទាមទារបិទរូបថតថ្នាក់ដឹកនាំសហជីព នៅក្នុងក្រុមហ៊ុន

- ភាគីសហជីពទាមទារឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យបិទរូបថតថ្នាក់ដឹកនាំសហជីពនៅក្នុងក្រុមហ៊ុន ពីព្រោះសហជីពបានទទួលការចុះបញ្ជិកាត្រឹមត្រូវពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចនេះសហជីពមានសិទ្ធិបិទរូបថតថ្នាក់ដឹកនាំសហជីពនៅក្នុងក្រុមហ៊ុនបាន។
- នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១ សហជីពបានរៀបចំបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពប្រចាំក្រុមហ៊ុន ដែលមានលោក សាត សែប ជាប់ជាប្រធាន, លោក ស៊ុំ សុធា ជាប់ជាអនុប្រធាន និងលោក ជា សុផាត ជាប់ជាលេខាធិការ ។
- ភាគីសហជីពបញ្ជាក់ថា លោក ជា សុផាត បានលាឈប់ពីលេខាធិការសហជីពហើយ។ ដូចនេះ ភាគីសហជីពត្រូវការបិទតែរូបថតរបស់ប្រធាន និងអនុប្រធានសហជីពតែប៉ុណ្ណោះ។
- នៅថ្ងៃទី១៦ ឬថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១១ ភាគីសហជីពមិនបានចាំថ្ងៃពិតប្រាកដ ដែលសហជីពបានយកបញ្ជិកាសហជីពជូនទៅក្រុមហ៊ុននោះទេ។ ភាគីសហជីពទទួលស្គាល់ថា សហជីពមិនបានជូនដំណឹងទៅក្រុមហ៊ុនអំពីលទ្ធផលបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពទេ គឺរហូតដល់សហជីពទទួលការចុះបញ្ជិកាពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទើបសហជីពជូនដំណឹងទៅក្រុមហ៊ុន។
- នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១១ សហជីពបានដាក់លិខិតទៅក្រុមហ៊ុន ដើម្បីស្នើសុំបិទរូបថតថ្នាក់ដឹកនាំសហជីព នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១១។ ប៉ុន្តែ រហូតដល់កាលបរិច្ឆេទនេះ ក្រុមហ៊ុនមិនបានឆ្លើយតបទៅនឹងការស្នើសុំនេះទេ។ ភាគីសហជីពបានបញ្ជាក់ថា ដោយមូលហេតុមិនមានការឆ្លើយតបថា ព្រម ឬ មិនព្រមតាមការស្នើសុំនេះ សហជីពក៏បានទៅជួបប្រធានធនធានមនុស្សប្រចាំនៅក្រុមហ៊ុន ដើម្បីសួរបញ្ជាក់ និងស្នើសុំបិទរូបថតថ្នាក់ដឹកនាំសហជីពនេះ។ ប៉ុន្តែ ប្រធានធនធានមនុស្សមិនអនុញ្ញាតឱ្យបិទរូបថតថ្នាក់ដឹកនាំសហជីពនៅក្នុងក្រុមហ៊ុនទេ។
- ភាគីសហជីពបានបញ្ជាក់នូវមូលហេតុនៃការទាមទារនេះ គឺដើម្បីឱ្យកម្មករនិយោជិតបានស្គាល់ និងទទួលស្គាល់ពួកគាត់ជាថ្នាក់ដឹកនាំសហជីព ដែលជាតំណាងស្របច្បាប់របស់ពួកគាត់។ ហើយនៅពេលដែលថ្នាក់ដឹកនាំសហជីពធ្វើទំនាក់ទំនងដោយផ្ទាល់ជាមួយកម្មករនិយោជិត ធ្វើឱ្យពួកគាត់មានទំនុកចិត្តមកលើសហជីពក្នុងការបំរើផលប្រយោជន៍ដល់ពួកគាត់ ដែលច្បាប់បានកំណត់។
- ភាគីសហជីពបានបញ្ជាក់ថា ការទាមទារនេះ គឺផ្អែកលើមាត្រា ២៨៨ និងមាត្រា ២៧៥ នៃច្បាប់ស្តីពីការងារ។

ចំណុចវិវាទទី២ ៖ កម្មករនិយោជិតទាមទារសុំបន្ទប់របស់ក្រុមហ៊ុនសម្រាប់សហជីពបានជួបប្រជុំរយៈពេល ១ ម៉ោង ក្រៅម៉ោងការងារ ក្នុងរយៈពេល ២ សប្តាហ៍ ម្តងរាល់ខែ

- ភាគីសហជីពបញ្ជាក់ថា សហជីពទាមទារសុំបន្ទប់ក្នុងក្រុមហ៊ុនសម្រាប់សហជីពប្រជុំ១ម៉ោង ក្រៅម៉ោងការងារក្នុងរយៈពេល ២ សប្តាហ៍ ម្តងរាល់ខែ ពីព្រោះកន្លងមក ក្រុមហ៊ុនក៏បានរៀបចំបន្ទប់ដល់អង្គការនានា ដូចជាអង្គការ HIV សម្រាប់ធ្វើការផ្សព្វផ្សាយការអប់រំ និងការបង្ការអំពីជំងឺអេសដ៍ ដល់កម្មករនិយោជិត។ ហេតុនេះ សហជីពក៏ស្នើសុំក្រុមហ៊ុនធ្វើដូចគ្នានេះដែរ។
- ភាគីសហជីពបានបញ្ជាក់ថា សហជីពទាមទារសុំបន្ទប់សម្រាប់សហជីពប្រជុំនេះ គឺដើម្បីផ្សព្វផ្សាយអំពីវិន័យ សីលធម៌ ច្បាប់ស្តីពីការងារ និងច្បាប់ដ៏ទៃទៀត ពីព្រោះកន្លងមក កម្មករនិយោជិតមិនទទួលបានការអប់រំផ្សព្វផ្សាយទេ។ ឧទាហរណ៍ដូចជាអ្នកបំរើការលើកភេសជ្ជៈដាក់ជូនភ្ញៀវ នៅពេលភ្ញៀវឱ្យប្រាក់ធីប ហើយគាត់យកប្រាក់នោះទុក ពេលកាំមេរ៉ាចាប់បាន ក្រុមហ៊ុនបញ្ឈប់គាត់ពីការងារ។ នេះដោយសារគាត់មិនទទួលបានការអប់រំ និងផ្សព្វផ្សាយឱ្យបានដឹងថា ទង្វើរនេះខុសនឹងវិធានការរបស់ក្រុមហ៊ុន។ បើគាត់ដឹង គាត់មិនធ្វើទេ។
- ភាគីសហជីពបានបញ្ជាក់ថា មូលហេតុដែលសហជីពទាមទារសុំបន្ទប់ប្រជុំនេះ ដោយសារផ្អែកលើមាត្រា ២៧៥ នៃច្បាប់ស្តីពីការងារ ហើយក្រុមហ៊ុនមានតែសហជីពតែមួយគត់ គឺមិនមានតំណាងកម្មករ (ប្រតិភូបុគ្គលិក)ទេ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

មុននឹងធ្វើការបកស្រាយលើចំណុចវិវាទនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើអាជ្ញាកណ្តាលអាចបើកសវនាការដោយកំបាំងមុខនិយោជកដែរ ឬទេ?

ប្រការ ២១ នៃប្រកាសលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញសេចក្តីបង្គាប់"*។

ទាក់ទងនឹងខ្លឹមសារនៃប្រការ ២១ នៃប្រកាសលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ នៅក្នុងសំណុំរឿងមុនៗ នៅពេលដែលភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចបន្តដំណើរការរបស់ខ្លួនដោយអវត្តមានរបស់ភាគីនោះ។ ជាក់ស្តែងដូចជានៅក្នុងសំណុំរឿងលេខ ៥៣/០៤-គួងហុង និងសំណុំរឿងលេខ១៤៨/០៧-ប៉ាយហ៊ី ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចបន្តដំណើរការរបស់ខ្លួនដោយអវត្តមានរបស់ភាគីនិយោជក។

នៅក្នុងរឿងនេះ មានតែប្រធានសហជីពសេរីកម្មករនិយោជិតទេ ដែលចូលរួមសវនាការតាមការអញ្ជើញ

របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ប៉ុន្តែភាគីនិយោជកមិនបានចូលរួមសវនាការតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ហើយក៏មិនបានបង្ហាញមូលហេតុត្រឹមត្រូវអំពីការមិនចូលរួមនេះដែរ ។

ដូច្នេះ ដើម្បីឱ្យស្របតាមវិធាននៃច្បាប់ ក៏ដូចជាស្របនឹងសេចក្តីបង្គាប់ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ សម្រេចបន្តដំណើរការរបស់ខ្លួនដោយធ្វើការបើកសវនាការ ដោយកំបាំងមុខភាគីនិយោជក និងចំពោះមុខភាគីកម្មករនិយោជិតដើម្បីវិនិច្ឆ័យលើសំណុំរឿង ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ ដោយផ្អែកលើភស្តុតាង និងការបកស្រាយបំភ្លឺរបស់ប្រធានសហជីពនៅក្នុងសវនាការ ។

**ចំណុចវិវាទទី១ ៖ ការទាមទារសុំបិទរូបថតថ្នាក់ដឹកនាំសហជីពនៅក្នុងក្រុមហ៊ុន**

ក្នុងករណីនេះ សហជីពទាមទារសុំបិទរូបថតថ្នាក់ដឹកនាំហជីព និងសកម្មភាពសហជីព នៅក្នុងក្រុមហ៊ុន ដើម្បីឱ្យកម្មករនិយោជិតបានស្គាល់ និងមានទំនុកចិត្តក្នុងការបំរើផលប្រយោជន៍ ដែលច្បាប់បានកំណត់ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដូចខាងក្រោម៖

ភាគីសហជីពបានលើកឡើងថា ការទាមទារនេះ គឺផ្អែកលើមាត្រា ២៨៨ និងមាត្រា ២៧៥ នៃច្បាប់ស្តីពីការងារ ។

មាត្រា ២៨៨ នៃច្បាប់ស្តីពីការងារចែងថា *"ប្រតិភូបុគ្គលិក ត្រូវបានជ្រើសរើសក្នុងចំណោមបេក្ខជនជ្រើសតាំងដោយអង្គការសហជីព ដែលមានភាពជាតំណាងបានជ្រើសតាំងនៅក្នុងក្របខ័ណ្ឌគ្រឹះស្ថានទីមួយៗ..."* ។

មាត្រា ២៧៥ នៃច្បាប់ស្តីពីការងារចែងថា *"អង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត និងរបស់និយោជក ដែលមានចែងក្នុងមាត្រា ២៦៦ អាចពិគ្រោះគ្នាដោយសេរីក្នុងការសិក្សាស្រាវជ្រាវការលើកតម្កើង និងការការពារផលប្រយោជន៍ខាងស្មារតី និងសំភារៈ..."* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ២៨៨ និងមាត្រា ២៧៥ នៃច្បាប់ស្តីពីការងារខាងលើ មិនទាក់ទងនឹងការបិទរូបថតថ្នាក់ដឹកនាំសហជីពនៅក្នុងក្រុមហ៊ុនទេ ។ ផ្ទុយទៅវិញ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា មានវិធានច្បាប់ផ្សេងទៀតបានចែងអំពីបញ្ហានេះ គឺ ៖

កថាខ័ណ្ឌទី២ នៃសារាចរលេខ ៤០ សកអ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៩៨ របស់ក្រសួងទទួលបន្ទុកវិស័យការងារចែងថា *"ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានត្រូវផ្តល់កន្លែងសមស្របសម្រាប់ប្រតិភូបុគ្គលិក និងអង្គការសហជីពបិទផ្សាយឈ្មោះ រូបថត មុខងារ និងរបស់ប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីព ព្រមទាំងសកម្មភាពរបស់ខ្លួន "* ។

ក្នុងសំណុំរឿងលេខ ១០៦/០៦-ឃ្មីកស៊ូ ចំណុចវិវាទទី២ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចថា និយោជកត្រូវផ្តល់កន្លែងសមស្របសម្រាប់ឱ្យសហជីពបិទផ្សាយឈ្មោះ រូបថត និងមុខងាររបស់ថ្នាក់ដឹកនាំសហជីពព្រមទាំងសកម្មភាពរបស់សហជីព ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ ។

នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១១ គាត់បានដាក់លិខិតទៅក្រុមហ៊ុនស្នើសុំបិទរូបថតថ្នាក់ដឹកនាំសហជីព និងសកម្មភាពសហជីព នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១១។ ប៉ុន្តែ រហូតដល់កាលបរិច្ឆេទនេះ ក្រុមហ៊ុនមិនបានឆ្លើយតបទៅនឹងការស្នើសុំនេះទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការខកខានមិនបានឆ្លើយតបទៅនឹងការស្នើសុំ និងមិនអនុញ្ញាតឱ្យបិទរូបថតថ្នាក់ដឹកនាំសហជីព និងសកម្មភាពសហជីព គឺជាការអនុវត្តមិនត្រឹមត្រូវតាមសារាចរលេខ ៤០ ទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ឱ្យនិយោជកត្រូវផ្តល់កន្លែងសមស្របសម្រាប់ឱ្យសហជីព បិទរូបថត ថ្នាក់ដឹកនាំសហជីព និងសកម្មភាពសហជីព។

**ចំណុចវិវាទទី២ ៖ កម្មករនិយោជិតទាមទារសុំបន្ទប់របស់ក្រុមហ៊ុនសម្រាប់សហជីពបានជួបប្រជុំរយៈពេល ១ ម៉ោង ក្រៅម៉ោងការងារ ក្នុងរយៈពេល ២ សប្តាហ៍ ម្តងរាល់ខែ**

មាត្រា ២៧៥ នៃច្បាប់ស្តីពីការងារចែងថា *"អង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត និងរបស់និយោជកដែលមានចែងក្នុងមាត្រា ២៦៦ អាចពិគ្រោះគ្នាដោយសេរីក្នុងការសិក្សាស្រាវជ្រាវការលើកតម្កើង និងការការពារផលប្រយោជន៍ខាងស្មារតី និងសំភារៈ..."*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ២៧៥ នៃច្បាប់ស្តីពីការងារខាងលើ មិនបានតម្រូវឱ្យនិយោជកផ្តល់បន្ទប់សម្រាប់សហជីពប្រជុំក្រៅម៉ោងការងារ នៅក្នុងក្រុមហ៊ុនទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មិនមានបទប្បញ្ញត្តិក្នុងច្បាប់ស្តីពីការងារ តម្រូវឱ្យនិយោជកផ្តល់បន្ទប់ប្រជុំសម្រាប់សហជីពទេ។ សិទ្ធិនេះបានផ្តល់ឱ្យតែតំណាងប្រតិភូបុគ្គលិកប៉ុណ្ណោះ ដូចមានចែងក្នុងប្រការ ៦ នៃប្រកាសលេខ ២៨៦ សកបយ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០០ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ស្តីពីប្រតិភូបុគ្គលិកនៅក្នុងសហគ្រាស គ្រឹះស្ថាន។

លើសពីនេះទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកមិនឃើញថា និយោជក និងកម្មករនិយោជិតមានកិច្ចព្រមព្រៀង ឬអនុសញ្ញាណាមួយ ដែលតម្រូវឱ្យនិយោជកផ្តល់បន្ទប់ប្រជុំសម្រាប់សហជីពទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទាររបស់កម្មករនិយោជិត គឺទាមទារពីផលប្រយោជន៍ ដែលលើសពីច្បាប់ផ្តល់ឱ្យ។ ដូចនេះ ការទាមទារនេះ គឺជាវិវាទអំពីផលប្រយោជន៍ ។

ជាទូទៅ ចំពោះវិវាទទាក់ទងនឹងផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលតែងតែពិចារណាលើភាពជាតំណាងបំផុតរបស់សហជីព ដែលជាភាគីវិវាទ។ នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធពិចារណាវិវាទអំពីផលប្រយោជន៍ ប្រសិនបើសហជីពដែលនាំវិវាទការងារនោះមក ជាសហជីពដែលមិនមានភាពតំណាងបំផុតនៅក្នុងរោងចក្រ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ*០២/១១-ពូយៀន ហេតុផលចំណុចវិវាទទី២ និងលេខ ៦៦/១១-អ៊ិន ហាន ស៊ុង ហេតុផលចំណុចវិវាទទី១*)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាពជាតំណាងបំផុតរបស់សហជីពនេះ ផ្តល់សិទ្ធិតាមផ្លូវច្បាប់ក្នុងការចរចាបង្កើតអនុសញ្ញារួមក្នុងក្រុមហ៊ុន និងមានសិទ្ធិស្របច្បាប់ក្នុងការនាំសំណុំរឿងវិវាទអំពីប្រយោជន៍មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយ។

ដើម្បីទទួលបានភាពជាតំណាងបំផុត មាត្រា ២៧៧ នៃច្បាប់ស្តីពីការងារ និងប្រការ ៦ នៃប្រកាសលេខ ៣០៥ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ តម្រូវឱ្យសហជីពនោះមានសមាជិកយ៉ាងហោចណាស់ច្រើនជាងពាក់កណ្តាលនៃចំនួនកម្មករនិយោជិតទាំងអស់ក្នុងរោងចក្រ ហើយត្រូវចុះបញ្ជិកានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងត្រូវបំពេញតាមលក្ខខណ្ឌផ្សេងៗទៀត ដែលមានចែងក្នុងមាត្រានេះ ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗខាងលើដែរ។

តាមអង្គហេតុ សហជីពសេរីកម្មករនិយោជិតមានសមាជិកតែ ១១០ នាក់ នៃចំណោមកម្មករនិយោជិតយ៉ាងតិច ៦៧២ នាក់ ហើយពុំទាន់មានភាពជាតំណាងបំផុតនៅក្នុងក្រុមហ៊ុនទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សហជីពនេះពុំទាន់មានលក្ខណៈគ្រប់គ្រាន់តាមផ្លូវច្បាប់ ក្នុងការធ្វើជាតំណាងឱ្យកម្មករនិយោជិតដើម្បីដោះស្រាយវិវាទ ដែលទាក់ទងទៅនឹងផលប្រយោជន៍រួមរបស់កម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុននៅឡើយទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់សហជីព ឱ្យនិយោជកផ្តល់បន្ទប់ក្នុងក្រុមហ៊ុនសម្រាប់សហជីពប្រជុំរយៈពេល១ម៉ោង ក្រៅម៉ោងការងារក្នុងរយៈពេល២សប្តាហ៍ ជារៀងរាល់ខែ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

ចំណុចវិវាទទី១ ៖ បង្គាប់ឱ្យនិយោជកផ្តល់កន្លែងសមស្របសម្រាប់ឱ្យសហជីពបិទរូបថតថ្នាក់ដឹកនាំសហជីព និងសកម្មភាពសហជីព។

ចំណុចវិវាទទី២ ៖ បដិសេធពិចារណាការទាមទាររបស់សហជីព ឱ្យនិយោជកផ្តល់បន្ទប់ក្នុងក្រុមហ៊ុនសម្រាប់សហជីពប្រជុំរយៈពេល១ម៉ោង ក្រៅម៉ោងការងារ ក្នុងរយៈពេល ២ សប្តាហ៍ ជារៀងរាល់ខែ។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិន ជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **សេង ទូចហ៊ុន**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ទួន ស៊ីផាន់**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា: ------------------------------